*អត្ថបទបកប្រែពីភាសាអង់គ្លេស*

# សេចក្តីថ្លែងការណ៍ក្នុងស្រុករបស់សហភាពអឺរ៉ុប ស្តីពី ស្ថានភាពនយោបាយនៅក្នុងប្រទេសកម្ពុជា

ដោយមានឯកភាពជាមួយប្រមុខបេសកកម្មការទូតរបស់សហភាពអឺរ៉ុបនៅក្នុងប្រទេសកម្ពុជា ប្រតិភូសហភាពអឺរ៉ុប សូមចេញនូវសេចក្តីថ្លែងការណ៍ដូចខាងក្រោមៈ

ប្រមុខបេសកកម្មការទូតនៃសហភាពអឺរ៉ុបនៅរាជធានីភ្នំពេញ មានជំនឿថាវានឹងផ្តល់ប្រយោជន៍ដល់ប្រទេសកម្ពុជា ហើយវាក៏នឹងផ្តល់ប្រយោជន៍ដល់ស្ថេរភាពយូរអង្វែងនៅក្នុងប្រទេសនេះដែរ ដើម្បីអោយមានការបោះឆ្នោតមួយដែលមានការជឿទុកចិត្តពីអ្នកបោះឆ្នោត ហើយដែលអនុញ្ញាតឱ្យប្រជាជនកម្ពុជាអាចធ្វើការជ្រើសរើសអ្នកដែលពួកគេមានបំណងចង់ឲ្យធ្វើជាតំណាងរបស់ពួកគេនៅថ្នាក់ឃុំនិងថ្នាក់ជាតិ។ ហេតុដូច្នេះហើយ ទើបសហភាពអឺរ៉ុប បានធ្វើការគាំទ្រ និងកំពុងគាំទ្រដល់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ក្នុងរការរៀបចំបញ្ជីឈ្មោះអ្នកបោះឆ្នោតថ្មី។

នៅក្នុងបរិបទនេះ យើងសូមរំពឹងលើអាជ្ញាធរដើម្បីធ្វើការធានាអោយមានបរិយាកាសមួយដែលក្នុងនោះគណបក្សប្រឆាំង និង សង្គមស៊ីវិលទាំងឡាយ អាចដំណើរការបានដោយសេរី ។ បរិយាកាសនៃការបោះឆ្នោតនេះ ត្រូវបានរងផលប៉ះពាល់ជាអវិជ្ជមានដោយការអនុម័តច្បាប់នៅក្នុងរដ្ឋសភាជាតិកាលពីថ្ងៃទី ២០ ខែ កុម្ភៈ ដែលជាសក្តានុពល នឹងអនុញ្ញាតឱ្យមានការរឹតត្បិតតាមអំពើចិត្តលើសកម្មភាពរបស់គណបក្សនយោបាយនានា ឬអោយមានការរំលាយគណៈបក្សទាំងនោះ ។ សកម្មភាពបែបនេះលើគណបក្សប្រឆាំង នឹងនាំទៅដល់ការចោទសួរលើភាពស្របច្បាប់នៃការបោះឆ្នោតនាខាងមុខ។

រាជធានីភ្នំពេញ ថ្ងៃទី ២២ ខែ កុម្ភៈ ឆ្នាំ ២០១៧